# អគ្គិសនីកម្ពុជា

## កម្មវិធី
## អភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ
## របស់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូប-
## នីយកម្មជនបទ នៃអគ្គិសនីកម្ពុជា
## ( ម.អ.ជ. )




**អាសយដ្ឋាននាយកដ្ឋាន ម.អ.ជ.៖**

អគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ទូរស័ព្ទៈ (៨៥៥) ៩៩៧ ៦០០ ទូរសារៈ (៨៥៥) ៩៩៧ ៦០១

គេហទំព័រៈ www.ref.gov.kh

## ១. គោលនយោបាយ និងយុទ្ធសាស្ត្រអគ្គិសនីភាវូប-នីយកម្មជនបទរបស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** តំណាងដោយក្រសួងរ៉ែ និងថាមពល ដែលជាស្ថាប័នជំនាញបានបង្កើតគោលនយោបាយ លើកទឹកចិត្ត និង ជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីឆ្លើយតបទៅនឹង សេចក្តីត្រូវការប្រើប្រាស់អគ្គិសនីរបស់ប្រជាពលរដ្ឋ និងសង្គម។ គោលដៅរបស់រាជរដ្ឋាភិបាល គឺដល់ឆ្នាំ២០២០ ភូមិទាំងអស់ទូទាំង ព្រះរាជាណាចក្រកម្ពុជា នឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពផ្សេងៗ និងដល់ឆ្នាំ២០៣០ យ៉ាងហោច ៧០% នៃគ្រួសារទាំងអស់ទូទាំង ព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនី ដែលមានគុណភាពដូច អគ្គិសនីពីបណ្តាញជាតិប្រើប្រាស់។

ដើម្បីជាចំណែកជំរុញឲ្យសម្រេចគោលដៅនេះ រាជរដ្ឋាភិបាល បានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្ម ជនបទ ដើម្បីជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ដោយ ប្រើប្រាស់ប្រភពថវិកាជំនួយរបស់ធនាគារពិភពលោកក្រោមគម្រោង អគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន និងថវិកាបដិភាគរបស់ រាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់មកនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/ ០៨១២/៧៣៤ ស្តីពីការធ្វើវិសោធនកម្មមាត្រាខ្លះ នៃព្រះរាជក្រឹត្យ ចាស់ ផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឲ្យស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ។

គោលបំណងនៃព្រះរាជក្រឹត្យនេះ គឺដើម្បី ១- ជំរុញឲ្យមាន សមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឲ្យប្រជាជននៅ ជនបទ បានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃ ដែលអាចជាវបាន សម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅដ្ឋាន រួមចំណែកកាត់បន្ថយភាព ក្រីក្រ ២- ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគធ្វើ សេវាកម្មអគ្គិសនីនៅជនបទប្រកបដោយចីរភាព ជាពិសេសក្នុងការ អនុវត្តបច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញ ដែលមានលក្ខណៈ បច្ចេកទេស និងពាណិជ្ជកម្មសមស្រប។

បច្ចុប្បន្ន នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា បន្ទាប់ពីនេះហៅថា "ម.អ.ជ." មានកម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទចំនួន៣ រួមមាន៖ ១- កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ២- កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និង៣- កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

## ២. ប្រភពមូលនិធិ

ប្រភពមូលនិធិដល់ ម.អ.ជ. មានដូចខាងក្រោម៖

១. កញ្ចប់ថវិកាសង្គមកិច្ច ដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ប្រសិនបើមាន។

២. អំណោយ និងជំនួយឥតសំណង ដែលប្រភពនិងលក្ខខណ្ឌនៃការផ្តល់ ត្រូវបានទទួលការឯកភាពពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣. ថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។

## ៣. កម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ

### *៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រជនបទ*

គោលបំណងនៃកម្មវិធី គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យគ្រួសារទាំងនេះអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យគ្រួសារជនបទខ្ចីយកទៅ៖ ១- បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២- បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣- ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង៤- ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនីដែលជាអ្នកទទួលខុសត្រូវក្នុងការបង់សងត្រឡប់មក ម.អ.ជ. វិញ ដោយបានមកពីការប្រមូលពីអ្នកខ្ចី ដែលត្រូវបង់សងរំលស់១ខែម្តងមក ម.អ.ជ. ក្នុងរយៈពេល ៣៦ខែ។ ចំនួនទឹកប្រាក់កម្ចីអនុគ្រោះនេះ

គឺមិនលើសពី 480,000 រៀល ក្នុង១គ្រួសារ។ សម្ភារៈ និងឧបករណ៍ទាំងអស់ដែលបានតម្លើង ក្នុងរយៈពេលដែលអ្នកខ្ចីពុំទាន់បង់សងអស់ គឺជាកម្មសិទ្ធិរបស់អ្នកផ្គត់ផ្គង់អគ្គិសនី។ បន្ទាប់ពីអ្នកខ្ចីបានសងប្រាក់កម្ចីអនុគ្រោះនេះគ្រប់ចំនួនមក ម.អ.ជ. រួចមក ប្រាក់កក់ និងសម្ភារៈទាំងអស់ ដែលបានតម្លើងនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកខ្ចី។





## ៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធី គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាលដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ ម.អ.ជ. នឹងជួយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ ដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធមួយផ្នែក ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធនមក ម.អ.ជ. វិញ។ ម.អ.ជ. នឹងតម្លើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យដល់ផ្ទះអ្នកទិញ ហើយអ្នកទិញអាចជ្រើសរើសជម្រើសបង់តម្លៃសល់ នៃថ្លៃប្រព័ន្ធក្នុងចំណោមជម្រើសចំនួន៣ គឺ៖ ជម្រើសទី១- បង់គ្រប់ចំនួនតែម្តងនៃតម្លៃសល់ ឬជម្រើសទី២- បង់សងរំលស់តម្លៃសល់រៀងរាល់ ៦ខែម្តង រហូតដល់គ្រប់ចំនួនសម្រាប់រយៈពេល ៤ឆ្នាំ ឬជម្រើសទី៣- បង់សងរំលស់តម្លៃសល់រៀងរាល់ខែរហូតដល់គ្រប់ចំនួន សម្រាប់រយៈពេល ៤ឆ្នាំ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

បរិក្ខាប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ដែលត្រូវតម្លើងឲ្យអ្នកទិញមាន ដូចខាងក្រោម៖

- ផ្ទាំងកញ្ចក់ស្រូបពន្លឺព្រះអាទិត្យដែលមានអានុភាព ៥០វ៉ាត់ ចំនួន ១ផ្ទាំង។
- ឧបករណ៍ត្រួតពិនិត្យ (តង់ស្យុង ១២វ៉ុល ចរន្តជាប់) ចំនួន ១គ្រឿង។
- អាគុយកំលាំង ៥៥ អាំពែរម៉ោង (តង់ស្យុង១២វ៉ុល ចរន្តជាប់) ចំនួន ១គ្រឿង។
- អំពូលបំភ្លឺសន្សំថាមពល ១២វ៉ុល អានុភាព ៧វ៉ាត់ ចរន្តជាប់ ចំនួន ២គ្រឿង និង
- ឧបករណ៍បន្ទាប់បន្សំ សម្រាប់ការតម្លើងប្រព័ន្ធថាមពលពន្លឺ ព្រះអាទិត្យតាមផ្ទះ។









## ៣.៣ *កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ*

គោលបំណងនៃកម្មវិធី គឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីឯកជននៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនេះ ចែកចេញជា ៣តំបន់ ផ្អែកលើដង់ស៊ីតេប្រជាពលរដ្ឋ ដូចខាងក្រោម៖

**តំបន់ទី១-	តំបន់មានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច**

ម.អ.ជ. នឹងផ្តល់ការធានាលើការខ្ចីប្រាក់ពីធនាគារក្នុងស្រុករបស់អ្នកកាន់អាជ្ញាប័ណ្ណនៅតំបន់ជនបទ ដើម្បីយកទៅវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន។

**តំបន់ទី២-	តំបន់មានប្រជាពលរដ្ឋរស់នៅមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំចំណេញប្រសិនបើអ្នកផ្គត់ផ្គង់អគ្គិសនី ត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ**

ម.អ.ជ. ផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

**តំបន់ទី៣-	តំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកលើទុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី**

ម.អ.ជ. ផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីដោយពុំយកការប្រាក់ សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។




